# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៤០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ២ ថ្មី(ពីរ) នៃអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ២ ថ្មី នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា២ ថ្មី នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

/.

- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

## សម្រេច

**មាត្រា ១.-**

មាត្រា២ ថ្មី(ពីរ) នៃអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា២ ថ្មី នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលមាត្រា២ នៃអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ត្រូវបានកែសម្រួលដូចតទៅ ៖

**មាត្រា ២ ថ្មី (បី).-**

សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣. | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៤. | តំណាងក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥. | ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស | អនុប្រធាន |
| ៦. | តំណាងនិយោជក | អនុប្រធាន |
| ៧. | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨. | តំណាងក្រសួងផែនការ | សមាជិក |
| ៩. | តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១០. | តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១១. | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១២. | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៣. | តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១៤. | តំណាងក្រសួងកិច្ចការនារី | សមាជិក |
| ១៥. | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦. | តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៧. | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១៨. | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩. | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០. | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២១. | តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២២. | តំណាងក្រសួងបរិស្ថាន | សមាជិក |

២៣.ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ — សមាជិក
២៤. តំណាង០៤ រូប របស់និយោជក — សមាជិក
២៥. តំណាង០១ រូប របស់សភាពាណិជ្ជកម្ម — សមាជិក
២៦. តំណាង០២ រូប របស់និយោជិត — សមាជិក
២៧. តំណាង០៣ រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល — សមាជិក
២៨. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ — នាយកប្រតិបត្តិ។

គណៈកម្មាធិការជាតិនេះអាចអញ្ជើញតំណាង ០៣ រូប របស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមបាន។

គណៈកម្មាធិការជាតិនេះ មានអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ